## ការចិញ្ចឹមជន្លេនក្រហមជាចំណីមាន់-ទា

### ព័ត៌មានទូទៅ

ជន្លេនគឺជាសត្វម្យ៉ាង ដែលមានប្រយោជន៍ច្រើន មុខចំពោះការងារចិញ្ចឹមសត្វ និងការដាំដំណាំផ្សេងៗ ។

ជន្លេនជាសត្វងាយស្រួលចិញ្ចឹម សំបូរទៅដោយប្រូតេអ៊ីនខ្ពស់ ជាចំណីសំរាប់សត្វមាន់ ទា ជ្រូក ត្រី និង កង្កែបជាដើម ។

### ការជ្រើសរើសទីតាំងសំរាប់ជីករណ្តៅ



- កន្លែងមានដីខ្ពស់ល្មម មិនលិចទឹក មិនក្តៅស្ងួតខ្លាំង
- ដីមានម្លប់ត្រជាក់ និងខ្យល់ចេញចូលបានល្អ

### ២. ការរៀបចំរណ្តៅចិញ្ចឹមជន្លេន

ទំហំរណ្តៅដែលសមស្របមាន:

- បណ្តោយប្រវែង២ម ទទឹង១ម និង ជំរៅ០,៣ម ។



- ត្រូវទ្រាប់ក្រណាត់ប្លាស្ទិកនៅបាតរណ្តៅ
- បាំងបន្ទះក្តារជុំវិញជៀសវាងដីបាក់ចូលក្នុងរណ្តៅ
- ទំលុះរន្ធតូចៗ ចំងាយពីគ្នា ១សង់ទីម៉ែត្រ ។

### ៣. ការផ្តល់ចំណីអោយជន្លេន

ចំណីសំរាប់ដាក់អោយជន្លេនស៊ីមាន: លាមកគោ លាមកសេះ ពពែស្រស់ និងកាកសំណល់ផ្ទះបាយ ។

- ដំបូងត្រូវដាក់ដីទ្រាប់បាត កំរាស់ ៥សង់ទីម៉ែត្រ ។ រួចកៀរអោយស្មើមុននឹងដាក់លាមកគោស្រស់ចូល ។
- ប្រើលាមកគោស្រស់ ចំនួន ១០០គ.ក ដោយបំបែក អោយម៉ត់មានកំរាស់ ១០សង់ទីម៉ែត្រ ។

### ៤. ការដាក់លាមកគោស្រស់និងពូជជន្លេនសំរាប់ចិញ្ចឹម

- នៅពេលដាក់លាមកគោរួច ត្រូវយកពូជជន្លេន ដាក់ក្នុងលាមកគោនោះចំនួន៤-៥កន្លែង ។
- ពូជជន្លេនត្រូវប្រើមានចំនួន១គីឡូក្រាម (គិតទាំងជន្លេន និងលាមកសត្វ) ក្នុងផ្ទៃរណ្តៅ ១ម៉ែត្រការ៉េ ។



- បន្ទាប់ពីដាក់ពូជជន្លេនហើយ ត្រូវស្រោចទឹកអោយសើមល្មម ជៀសវាងកុំអោយទឹកជោគពេក ។

